ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

ក្រសួងមហាផ្ទៃ

លេខ: ០០៣.ក៧ហ

# កំណត់ហេតុ

ថ្ងៃសុក្រ ដប់រោច ខែកត្តិក ឆ្នាំខាល ចត្វាស័ក ពុទ្ធសករាជ ពីរពាន់ប្រាំរយហុកសិបប្រាំមួយ ត្រូវនឹងថ្ងៃទីដប់ប្រាំបី ខែវិច្ឆិកា ឆ្នាំពីរពាន់ម្ភៃពីរ វេលាម៉ោងប្រាំបី និងសាមសិប នាទីព្រឹក នៅសាលប្រជុំអគារ T-27 ទីស្តីការក្រសួងមហាផ្ទៃ មានបើកកិច្ចប្រជុំស្តាប់របាយការណ៍ស្តីពី លទ្ធផលកិច្ចប្រតិបត្តិការចុះធ្វើអធិការកិច្ចហត្ថពលកម្មបរទេស នៅកាស៊ីណូ បាវិត-ម៉ុកបាយ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ។

**សមាសភាពអញ្ជើញចូលរួម ៖**

| | | | |
|---|---|---|---|
| ១.ឯកឧត្តម បណ្ឌិត | អ៊ិត | សំហេង | រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ២.ឯកឧត្តម | សក់ | សេដ្ឋា | រដ្ឋលេខាធិការប្រចាំការ ក្រសួងមហាផ្ទៃ |
| ៣.លោកជំទាវ | ឌុំ | ម៉ុនអេង | រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ |
| ៤.ឯកឧត្តម សន្តិបណ្ឌិត | សុខ | ផល | រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ |
| ៥.ឯកឧត្តម | ម៉ុន | ហុន | រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ |
| ៦.ឯកឧត្តម | នៅ | លក្ខណា | អនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ |
| ៧.ឯកឧត្តម | ទ្រី | សុខហេង | អនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ |
| ៨.ឯកឧត្តម | អ៊ុច | ចាន់ណូរ៉ា | អនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ |
| ៩.ឯកឧត្តម | សេង | សក្ដា | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានការងារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ១០.ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត | នេត | សាវឿន | អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ |
| ១១.ឯកឧត្តម | ប្រាក់ | សំអឿន | អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល |
| ១២.ឯកឧត្តម នាយឧត្តមសេនីយ៍ | គៀត | ចំន្ទថារិទ្ធ | អគ្គនាយក នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ |
| ១៣.ឯកឧត្តម នាយឧត្តមសេនីយ៍ | កែវ | ចណ្ណថន | អគ្គនាយករង នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ |
| ១៤.ឯកឧត្តម ឧត្តមសេនីយ៍ឯក | ផាត | សុផានិត | អគ្គលេខាធិការរង និងជាប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ នៃអគ្គលេខាធិការដ្ឋាន |
| ១៥.ឯកឧត្តម ឧត្តមសេនីយ៍ឯក | ឆាយ | គីមខឿន | អគ្គស្នងការរង នៃអគ្គស្នងការដ្ឋាននគរបាលជាតិ |
| ១៦.ឯកឧត្តម ឧត្តមសេនីយ៍ឯក | សុវណ្ណា | ពិសាខា | អគ្គនាយករង នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ |
| ១៧.ឯកឧត្តម ឧត្តមសេនីយ៍ឯក | សាយ | ម៉េងឈាង | អគ្គនាយករង នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម |
| ១៨.ឯកឧត្តម ឧត្តមសេនីយ៍ទោ | ហាស់ | សុត្ថា | ប្រធាននាយកដ្ឋាននៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ |
| ១៩.ឯកឧត្តម | គង់ | ឝុម្ភះ | អនុប្រធានលេខាធិការដ្ឋាន នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |

២០.លោកស្រី ឧត្តមសេនីយ៍ត្រី **លឹម ដារី** អនុប្រធាននាយកដ្ឋានសរុប និងស្ថិតិ (លេខាកត់ត្រា)

២១.លោកស្រី អនុសេនីយ៍ទោ **គង់ សម្ផស្ស** នាយផ្នែកនៃនាយកដ្ឋានសរុប និងស្ថិតិ (លេខាកត់ត្រា)

បន្ទាប់ពីមានប្រសាសន៍ស្វាគមន៍អង្គប្រជុំរួចមក **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** និងជាប្រធានអង្គប្រជុំ បានគូសបញ្ជាក់ថា ការជួបជុំនៅថ្ងៃនេះ ដើម្បីស្តាប់របាយការណ៍ ស្តីពីការត្រួតពិនិត្យហត្ថពលកម្មបរទេសនៅកាស៊ីណូបាវិត-ម៉ុកបាយ។ ដោយកន្លងមក បានទទួលប្រកាសអន្តរក្រសួង រវាងក្រសួងមហាផ្ទៃ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបង្កើតក្រុមការងារមួយ ដើម្បីចុះធ្វើការងារនេះនៅខេត្តស្វាយរៀង ពីព្រោះនៅទីនោះមានបទល្មើសច្រើន ដូច្នេះ ដើម្បីមានមូលដ្ឋានក្នុងការពិភាក្សា ស្នើ **ឯកឧត្តម នាយឧត្តមសេនីយ៍ គៀត ច័ន្ទថារិទ្ធ អគ្គនាយក នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍** អានរបាយការណ៍សង្ខេបស្តីពីលទ្ធផលកិច្ចប្រតិបត្តិការចុះធ្វើអធិការកិច្ចហត្ថពលកម្មបរទេស នៅកាស៊ីណូបាវិត-ម៉ុកបាយ មុនដាក់ជូនអង្គប្រជុំចូលរួមមានមតិយោបល់ ។

## ✤ ប្រសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម ប្រធានអង្គប្រជុំ

ខ្ញុំសូមកោតសរសើរ ចំពោះក្រុមការងារដែលបានសហការគ្នាយ៉ាងល្អ ពីព្រោះការងារនេះជាគោលដៅមួយដ៏ស្មុគស្មាញ។ ដូច្នេះ ស្នើគួរបន្ថែមយន្តការក្នុងការដោះស្រាយ ដោយសារគោលដៅត្រូវធ្វើមានច្រើនកន្លែង ជាពិសេសនៅតាមបណ្តារាជធានី-ខេត្ត ដែលមានការជាប់ពាក់ព័ន្ធ ។ ឧទាហរណ៍ ពេលដែលយើងបង្ក្រាបនៅខេត្តព្រះសីហនុ គឺក្រុមហ្នឹងបានរត់គេចខ្លួនទៅតាមបណ្តាខេត្តផ្សេងៗ ដូចជារាជធានីភ្នំពេញ និងខេត្តកណ្តាល ជាដើម។ ហេតុដូចនេះ តើយើងគួរប្រើយន្តការរដ្ឋបាលនៅហ្នឹងកន្លែងបន្ថែមដែរឬទេ? ដើម្បីឱ្យអាជ្ញាធរ ព្រះរាជអាជ្ញាចូលរួម និងមានភាពទទួលខុសត្រូវ ក៏ដូចជាកៀរគរកម្លាំង និងមធ្យោបាយសរុប ដើម្បីបំពេញការងារនេះបានលឿន ឆាប់សម្រេចដល់គោលដៅ ព្រោះមិនមែនទាក់ទងតែរឿងជាកពិន័យមួយទេ តែវាប៉ះពាល់ដល់សន្តិសុខជាតិរបស់យើង ចំពោះពលករដែលមានទិដ្ឋាការ ប៉ុន្តែមិនមានប័ណ្ណការងារ នោះគឺខុសច្បាប់ហើយ ។

## ✤ មតិ ឯកឧត្តមបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ខ្ញុំសូមគាំទ្រនូវប្រសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចក្រឡាហោម** និងគោលគំនិតចង្អុលណែនាំក្នុងប្រតិបត្តិការត្រួតពិនិត្យជនបរទេសធ្វើការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីឱ្យមានភាពស្របច្បាប់ សន្តិសុខ កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ជាតិយើង ហើយក៏សូមធ្វើការកោតសរសើរដល់ក្រុមការងារ ដែលបានចុះធ្វើប្រតិបត្តិការនៅក្រុងបាវិតដែលដោះស្រាយបាននូវបញ្ហាដ៏ធំមួយនេះ ប្រកបដោយការទទួលខុសត្រូវ មានភាពម៉ឺងម៉ាត់ និងទន់ភ្លន់ ដែលមិនធ្វើឱ្យប៉ះពាល់ដល់អ្នកវិនិយោគ។ កន្លងមក យើងបានរកឃើញអ្នកខុសច្បាប់អន្តោប្រវេសន៍មានពី ៧០% ទៅ ៨០% សង្ឃឹមថាក្រោយពីការធ្វើប្រតិបត្តិការនេះ អ្នកដែលប្រព្រឹត្តខុសច្បាប់នឹងមានការពិចារណាឡើងវិញ។

ខ្ញុំសូមគាំទ្រចំពោះយន្តការរបស់ **សម្តេចក្រឡាហោម** ដែលប្រគល់ភារកិច្ចនេះទៅដល់ស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីប្រតិបត្តិការការងារនេះនៅមូលដ្ឋានផ្ទាល់ដែលស្ថិតនៅក្រោមការដឹកនាំរបស់គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី-ខេត្ត និងស្របទៅនឹងអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** តែយើងក៏ត្រូវមានការប្រុងប្រយ័ត្នផងដែរចំពោះរឿងនេះ ប្រសិនបើយើងមានការធ្វេសប្រហែស អាចប៉ះពាល់ដល់ការវិនិយោគ

របស់ជនបរទេស។ ពាក់ព័ន្ធនឹងការងារនេះ ខ្ញុំសូមស្នើឱ្យមានការដឹកនាំរួមពី **សម្តេចក្រឡាហោម** ឬជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចំពោះក្រុមប្រតិបត្តិការដែលដឹកនាំដោយ **ឯកឧត្តម នៅ លក្ខណា** អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ ជាយន្តការមួយ និងជាសេនាធិការជូន **សម្តេច** ឬក្រសួងការងារ និងជាក្រុមជួយតម្រង់ទិសដល់ប្រតិបត្តិការនៅតាមបណ្តាខេត្ត ។

នៅថ្ងៃក្រោយយើងនឹងអាចរៀបចំបណ្តាញជាមួយក្រុមហ៊ុនទាំងនោះ ដើម្បីផ្តល់ព័ត៌មានជុំវិញបញ្ហាទាំងនេះ។ បច្ចុប្បន្ន ខ្ញុំកំពុងរៀបចំសេចក្តីព្រាងច្បាប់ជាមួយ **ឯកឧត្តម ម៉ុន ហុន** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ ថាតើយើងត្រូវមានឯកសារអ្វីខ្លះ? ដើម្បីចូលទៅប្រទេសគេ ហើយពេលទៅដល់ត្រូវមានឯកសារអ្វីខ្លះទៀត? ចំពោះការផាកពិន័យទៅលើជនបរទេស យើងមានប្រកាសរួម រវាងក្រសួងការងារ និងបណ្តុះបណ្តាលនិងវិជ្ជាជីវៈ និងក្រសួងយុត្តិធម៌ សម្រាប់ច្បាប់ស្តីពីការងារ ដែលជារួមផាកពិន័យទូទៅចំនួន ៨០.០០០រៀល (ប្រាំបីម៉ឺនរៀល) ។ ដើម្បីដាក់ទម្ងន់ទៅលើជនខុសច្បាប់យើងតម្រូវឱ្យផាកពិន័យចំនួន ២០០.០០០រៀល (ម្ភៃម៉ឺនរៀល) តែបើប្រព្រឹត្តបទល្មើសត្រូវផាកពិន័យពី ៣.០០០ដុល្លារ (បីពាន់ដុល្លារ) ទៅ ១៥.០០០ដុល្លារ (មួយម៉ឺនប្រាំពាន់ដុល្លារ) ។

❖ **មតិ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ**

ខ្ញុំសូមគាំទ្រចំពោះការចង្អុលបង្ហាញដឹកនាំដ៏ខ្ពង់ខ្ពស់ និងមានប្រសិទ្ធភាពរបស់ **សម្តេចក្រឡាហោម** ដែលសម្រេចបានដោយជោគជ័យលើការងារប្រតិបត្តិការនៅក្រុងបាវិត ។ សរុបមកយើងបានរកឃើញជនបរទេសស្របច្បាប់ និងមិនស្របច្បាប់ដែលយើងត្រូវចាត់ការតាមវិន័យ និងតាមច្បាប់រដ្ឋបាល ហើយយើងក៏យកប្រតិបត្តិការនៅក្រុងបាវិតទុកធ្វើជាបទពិសោធន៍មួយដែរ ។ ចំពោះគោលដៅនោះយើងមិនបានរកឃើញមានការឃុំឃាំង ឬធ្វើទារុណកម្មទេ តែមានការសង្ស័យថាអាចមានល្បែងអនឡាញខុសច្បាប់ គឺផ្អែកលើមានកុំព្យូទ័រច្រើន ។ ចំណុចនេះបើធ្វើនៅកន្លែងផ្សេង យើងត្រូវយកកុំព្យូទ័រនេះមកពិនិត្យភ្លាម នោះយើងនឹងឃើញលទ្ធផលជាក់ស្តែងតែម្តង។ ការប្រតិបត្តិការនៅក្រុងបាវិត ដោយមានការសហការល្អ ជាមួយអាជ្ញាធរ និងម្ចាស់អាជីវកម្ម គឺយើងបានធ្វើការដោយភាពស្ងៀមស្ងាត់ ដែលនេះជាសារមួយសម្រាប់ទៅថ្ងៃក្រោយ ឱ្យក្រុមការងារយើងត្រូវបំពេញនៅកន្លែងផ្សេងទៀត ។

ពេលដែលយើងបានអនុវត្ត និងបង្កើតគណៈកម្មការទាំងបី (គណៈបញ្ជាការជួញដូរគ្រប់ទម្រង់ គណៈកម្មការល្បែងស៊ីសង និងគណៈកម្មការត្រួតពិនិត្យពលករបរទេសខុសច្បាប់) សហប្រតិបត្តិការព្រមគ្នាបានធ្វើឱ្យស្ថានការណ៍នៅប្រទេសកម្ពុជាល្អទាំងផ្នែកនយោបាយ និងផ្នែកការបរទេស ពិសេសចំពោះសន្តិសុខសង្គម ដែលប្រទេសយើងបានធ្វើជាប្រធានអាស៊ានឆ្នាំនេះ គឺជាមោទកភាពរបស់ជាតិ ។

ចំពោះទិសដៅបន្ត ខ្ញុំសូមគាំទ្រតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចក្រឡាហោម** និង **ឯកឧត្តម រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** គឺយើងត្រូវពង្រឹងយន្តការដែលមានស្រាប់ទៅជាយន្តការជំនាញមួយ និងជាសេនាធិការជូន **សម្តេច** ដើម្បីដឹកនាំការងារនេះទៅទូទាំងប្រទេស ។ សូមឱ្យខេត្តជាប្រធានចាត់ចែងដំណើរការ ប៉ុន្តែយើងត្រូវយកយន្តការថ្នាក់ជាតិដែលដឹកនាំដោយ **ឯកឧត្តម នៅ លក្ខិណា** ធ្វើជាបទពិសោធន៍បច្ចេកទេស សម្រាប់ណែនាំទៅដល់បណ្តាខេត្តនានា ដូចនេះត្រូវបន្តពង្រឹងការងារអន្តោប្រវេសន៍ថ្នាក់ក្រោមឱ្យមានសមត្ថភាពបន្ថែមទៀត និងរួមសហការជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ព្រមគ្នាតែម្តង ។

❖ មតិ ឯកឧត្តម សន្តិបណ្ឌិត សុខ ផល រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ

ខ្ញុំសូមចូលរួមយោបល់ចំនួន ៤ ចំណុច ៖

១.កន្លងមក យើងមានក្រុមការងារត្រួតពិនិត្យពលករបរទេសដែលមានលក្ខណៈតូចៗនៅគ្រប់បណ្តាខេត្តនានា តែក្នុង១ឆ្នាំ យើងចុះធ្វើបានតែម្តងប៉ុណ្ណោះ ហើយត្រឹមថ្នាក់អនុប្រធាននាយកដ្ឋានទៅទំនាក់ទំនងជាមួយស្នងការរងទទួលបន្ទុកអន្តោប្រវេសន៍ខេត្ត និងសូមការអនុញ្ញាតពីអភិបាលខេត្ត ដូច្នេះយើងធ្វើបានមិនដល់ ៥០% ផង ។

២.ការកែវិសោធនកម្មបទដ្ឋានច្បាប់អន្តោប្រវេសន៍ក្នុងមាត្រា ៣១ ដែលត្រូវផាកពិន័យចំពោះជនប្រព្រឹត្តល្មើសពី ២០០.០០០រៀល (ម្ភៃម៉ឺនរៀល) ទៅ ៥០០.០០០រៀល (ហាសិបម៉ឺនរៀល) ប្រសិនបើយើងធ្វើវិសោធនកម្មត្រឹមអនុក្រឹត្យលេខ១២៣ មិនទាន់គ្រប់គ្រាន់ទេ គឺត្រូវកែវិសោធនកម្មច្បាប់ការងារមកបន្ថែមទៀត ទើបអាចប្តូរផ្លាស់ខ្លឹមសារ នៃច្បាប់អន្តោប្រវេសន៍នេះបាន ។

៣.យើងមិនអាចយកប្រតិបត្តិការនៅក្រុងបាវិត ធ្វើជាគំរូបានទេ ពីព្រោះ ៖

ក. មុខរបររបស់ពួកគាត់មិនស្របច្បាប់ទេ

ខ. អគារមានរហូតដល់ ១៧កន្លែង ហើយអគារនីមួយៗមានកម្ពស់ទាបបំផុត ៥ជាន់

គ. អាជីវកម្មទាំងនោះប្រើប្រាស់កម្លាំងច្រើន ព្រោះបើតាមកំណត់យើងឱ្យប្រើបានត្រឹមតែ ១៥% ឬ២០% ប៉ុណ្ណោះ ។

៤.ពាក់ព័ន្ធគណៈកម្មការល្បែងពាណិជ្ជកម្មគាត់មានការតវ៉ាដែរ ថាមានការប៉ះពាល់ ជាពិសេសនៅតាមមូលដ្ឋាន។

❖ មតិ ឯកឧត្តម សត់ សេដ្ឋា រដ្ឋលេខាធិការប្រចាំការ ក្រសួងមហាផ្ទៃ

ការពិតយើងមានយន្តការដែលត្រួតពិនិត្យធ្វើអធិការកិច្ចការងារហ្នឹងនៅគ្រប់ខេត្ត គ្រាន់តែថាយន្តការនេះដើរទេ ? កន្លងមកម្ចាស់រោងចក្រមិនឱ្យយើងចូលទៅមើល ដូចនៅកាស៊ីណូបាវិត-ម៉ុកបាយ ឡើយ ដោយគ្រាន់តែឱ្យទៅកន្លែងរដ្ឋបាល ហើយយកបញ្ជីឈ្មោះមកមើលតែម្តង មិនមែនទៅបិទអាគារ ដើម្បីចូលត្រួតពិនិត្យផែកឆេរនោះទេ ដូចនេះវិធានការដែលយើងកំពុងអនុវត្តគឺនៅតែសើៗមិនទាន់ស៊ីជម្រៅទេ ។

ក្នុងករណីបើយើងត្រួតពិនិត្យ និងសង្ស័យថាមានល្បែងអនឡាញតាមរយៈកុំព្យូទ័រ យើងត្រូវយកកុំព្យូទ័រទាំងនោះមកធ្វើកោសល្យវិច័យ បើឃើញតម្រុយចោទប្រកាន់ ត្រូវបញ្ជូនរឿងហ្នឹង ដើម្បីបន្តនីតិវិធីតទៅទៀត ។

❖ មតិ ឯកឧត្តម នៅ លក្ខណា អនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ

ខ្ញុំសូមសង្ខេបខ្លឹមសារពីបញ្ហានេះគោរពជូន **សម្តេចក្រឡាហោម** មេត្តាជ្រាបជាខ្ពង់ខ្ពស់ថា ដូចប្រសាសន៍របស់ **ឯកឧត្តម រដ្ឋលេខាធិការប្រចាំការ** នៅក្នុងតួនាទីភារកិច្ចគណៈកម្មការអន្តរក្រសួង និយាយច្បាស់ពីការត្រួតពិនិត្យការចុះធ្វើហត្ថពលករបរទេស គឺបានឃើញនូវគ្រប់សកម្មភាព តែយើងធ្វើចំពោះពលករដែលខុសច្បាប់ប៉ុណ្ណោះ ។

ដើម្បីពង្រឹងយន្តការនេះឱ្យបានស៊ីជម្រៅ ត្រូវតែមានការចូលរួមសហការពីបណ្តាអាជ្ញាធរខេត្តនានា និងម្ចាស់អាជីវកម្មជាចាំបាច់ ព្រោះពេលដែលយើងចុះធ្វើការងារមានតែបញ្ជី ឬនៅខាងក្រៅ មិនបានទៅពិនិត្យជាក់ស្តែងតាមកន្លែងឱ្យបានច្បាស់លាស់ទេ ។

- ប្រសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម ប្រធានអង្គប្រជុំ

ខ្ញុំឯកភាព គឺយើងទៅធ្វើការងារនេះមិនមែនតាមចិត្តទេ ត្រូវតែមានច្បាប់ ហើយប្រយ័ត្នបំផុតនោះគឺចំពោះរោងចក្រ សហគ្រាស យើងត្រូវតែមានទំនាក់ទំនង ឬក៏យោងតាមច្បាប់ និងជម្រាបដល់គាត់ថាក្រុមការងារនឹងចុះមកធ្វើអធិការកិច្ច សូមឱ្យនិយោជកមានការសហការ ធ្វើយ៉ាងនេះពិតជាល្អ។ យើងក៏ត្រូវតែផ្តួចផ្តើមកសាងបណ្តាញនៅទីនោះ ដើម្បីយកព័ត៌មាន ធ្វើយ៉ាងណាឱ្យប្រទេសយើងមានសន្តិសុខល្អ ។

យើងត្រូវបង្កើតយន្តការបន្ថែមទៀត ស្នើ **ឯកឧត្តម រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** ជាប្រធានគណៈកម្មការ **ឯកឧត្តម សត់ សេដ្ឋា** អនុប្រធានទីមួយ **លោកជំទាវ ជូ ប៊ុនអេង** ទាក់ទងនឹងការជួញដូរមនុស្ស និងផ្នែកច្បាប់ ព្រមទាំងក្រសួងយុត្តិធម៌ផង និងមានផ្នែកផ្សេងៗទៀតគ្រប់ជំនាញជាក្រុមចម្រុះ ពេលរៀបចំក្រុមនេះហើយ និងអញ្ជើញអភិបាលខេត្តមកប្រជុំ ដើម្បីប្រគល់ភារកិច្ចជូនគាត់អនុវត្ត ។ ទន្ទឹមនេះ ពេលដែលយើងកំពុងរៀបចំក្រុមចម្រុះថ្មីនេះ ត្រូវផ្អាកប្រតិបត្តិការសិន បន្ទាប់ពីរៀបចំរួច ចាំចាប់ផ្តើមប្រតិបត្តិការការងារនេះឡើងវិញ ។

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោងដប់ និងហាសិបនាទី នាថ្ងៃ ខែ ឆ្នាំដដែល ក្រោមបរិយាកាសរីករាយ ស្និទ្ធស្នាល និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ៕

ថ្ងៃ ចន្ទ ១២កើត ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ២០២២

លេខាកត់ត្រា

ឧត្តមសេនីយ៍ត្រី ឈិម ផានិ

**អ្នកពិនិត្យកំណត់ហេតុ**

ថ្ងៃ ពុធ ១៤កើត ខែ បុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មករា ឆ្នាំ២០២៣

**អគ្គលេខាធិការរង**

**ឧត្តមសេនីយ៍ឯក ផាត សុផានិត**

**បានឃើញ និងឯកភាព**

ថ្ងៃ អង្គារ ៤រោច ខែ បុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មករា ឆ្នាំ២០២៣

ប្រធានអង្គប្រជុំ

**សម្តេចក្រឡាហោម ស ខេង**